# ព័ត៌មានស្តីអំពីការចាក់ថ្នាំបង្ការរោគ

ការចាក់ថ្នាំបង្ការរោគជួយការពារកុមារពីជម្ងឺធ្ងន់ធ្ងរជាច្រើន ដែលចេះតែកើតមាននៅក្នុងសហគមន៍ ហើយដែលកុមារនៅតែទទួលរងគ្រោះ ហើយស្លាប់ដោយមិនចាំបាច់។

ក្រុមប្រឹក្សាជាតិផ្នែកសុខភាព និងវេជ្ជសាស្ត្រ ណែនាំឲ្យមានគំរោងការជាតិលើការចាក់ថ្នាំបង្ការរោគសំរាប់គ្រប់ទាំងកុមារ។ លោកអ្នកគួរពិភាក្សាអំពីគំរោងការទាំងនេះជាមួយវេជ្ជបណ្ឌិត ឬមន្ទីរព្យាបាលរោគប្រចាំតំបន់របស់លោកអ្នក **និង/ឬមើលគេហទំព័រ NSW Health** (សុខភាពរដ្ឋញូវសៅវែល) **www.health.nsw.gov.au ដើម្បីមើលអំពីគំរោងការចាក់ថ្នាំបង្ការរោគរដ្ឋញូវសៅវែលបច្ចុប្បន្ន។**

ថ្នាំបង្ការរោគមានសំរាប់ការពារកុមារទប់ទល់នឹងរោគខាន់ស្លាក់ តេតាណូស ក្អកមាន់ ស្វិតដៃជើង អុតស្វាយ ស្រទ្បាទែនកញ្រ្ជឹល, រោគហ៊ិប (Hib) រោគរលាកថ្លើមប្រភេទ  B, ជម្ងឺមេនីញហ្គោខូខលប្រភេទ  B, រោគរលាកសួត និងអុតស្វាយ។ ថ្នាំបង្ការរោគទាំងនេះអាចទទួលយកបានពីវេជ្ជបណ្ឌិតប្រចាំតំបន់របស់លោកអ្នក សាលាក្រុងខ្លះ មន្ទីរពេទ្យកូនក្មេង មណ្ឌលសុខភាពសហគមន៍ និងកិច្ចបំរើផ្នែកវេជ្ជសាស្ត្រសំរាប់ជនជាតិដើម។

កុមារខ្លះកើតអាចកើតគ្រុនក្តៅបន្តិចបន្តួច និង/ឬឡើងក្រហម ហើម និងឈឺនៅត្រង់កន្លែងចាក់ថ្នាំ។ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនគ្រុនក្តៅមានកំរិតលើសពី៣៩អង្សា ឬប្រសិនបើលោកអ្នកព្រួយបារម្ភអំពីលក្ខណៈកូនរបស់លោកអ្នក។

គ្រប់ទាំងទារកបានដែលចុះឈ្មោះជាមួយមេឌីឃែរ (Medicare) ក៏មានចុះឈ្មោះផងដែរនៅក្នុងបញ្ជីចុះឈ្មោះការចាក់ថ្នាំបង្ការរោគកុមារភាពអូស្ត្រាលី (ACIR)។

បន្ទាប់ពីការចាក់ថ្នាំបង្ការរោគមួយលើកៗ វេជ្ជបណ្ឌិតប្រចាំតំបន់របស់លោកអ្នក ឬមន្ទីរព្យាបាលរោគនឹងផ្តល់ដំណឹងទៅ ACIR អំពីស្ថានភាពចាក់ថ្នាំបង្ការរោគរបស់កុមារ។

ACIR នឹងបញ្ជូនលិខិតបញ្ជាក់ពីប្រវត្តិចាក់ថ្នាំបង្ការរោគទៅលោកអ្នក កាលណាកូនរបស់លោកអ្នកបានបញ្ចប់នូវកម្មវិធីចាក់ថ្នាំបង្ការរោគរបស់វានៅក្នុងអាយុ៤ឆ្នាំ។ លោកអ្នកនឹងបានតម្រូវឲ្យប្រគល់លិខិតបញ្ជាក់នេះទៅសាលារៀនរបស់កូនលោកអ្នក នៅពេលចុះឈ្មោះចូលរៀន។

ប្រសិនបើលោកមិនបានទទួលលិខិតបញ្ជាក់នេះទេ ឬប្រសិនបើមានបញ្ហាជាមួយលិខិតបញ្ជាក់នេះ លោកអ្នកអាចទាក់ទងជាមួយ **ACIR** តាមទូរស័ព្ទលេខ **1800 653 809**។